# ចម្លាក់ព្រះគ្រឹស្នារកឃើញនៅខេត្តកំពង់ធំ

នៅក្នុងសិល្បៈខ្មែរ ចម្លាក់ព្រះគ្រឹស្នទ្រភ្នំគោវធ៌ន ចាប់ផ្តើមមានតាំងពីរវាងស.វ.ទី៦មកម្ល៉េះ ប៉ុន្តែគេឆ្លាក់ជាចម្លាក់ទោល។ លុះមកដល់ស.វ.ទី១០ ចម្លាក់ព្រះគ្រឹស្នទ្រភ្នំគោវធ៌ន ចាប់ផ្តើមមានភាពល្បីល្បាញយ៉ាងខ្លាំងនៅក្នុងសង្គមខ្មែរ ដូចឃើញឆ្លាក់នៅតាមផ្នែកជាច្រើននៃប្រាសាទ ដូចជា ហោជាង ផ្តែរទ្វារ សសរផ្តោប ជញ្ជាំង ។ល។ គេច្រើនឆ្លាក់រូបព្រះគ្រឹស្នមានពងសង្ហា មើលទៅមោះមុតក្លាហាន និងមានឫទ្ធានុភាពខ្លាំងខ្លា អាចលើកភ្នំគោវធ៌នទប់ជំនន់ទឹកភ្លៀងរបស់ព្រះឥន្ទ្របាន។ នៅក្នុងអត្ថបទមុន ធ្លាប់បានបង្ហាញអំពីចម្លាក់ព្រះគ្រឹស្នទ្រភ្នំគោវធ៌ន ដែលរកឃើញនៅតំបន់សំបូរព្រៃគុកម្តងរួចមកហើយ (រូបលេខ១)។ ដោយឡែក នៅក្នុងអត្ថបទខ្ទីនេះនឹងបង្ហាញជូនអំពីចម្លាក់ព្រះគ្រឹស្នទាំងអស់ ដែលរកឃើញនៅតាមប្រាសាទនានាក្នុងខេត្តកំពង់ធំ ហើយចម្លាក់ព្រះគ្រឹស្នទាំងនោះក៏មានមិនច្រើនដូចនៅតំបន់អង្គរដែរ ពោលគឺនៅមានចម្លាក់ចំនួន៤ទៀត។ ចម្លាក់ទាំងនោះមាន ចម្លាក់ព្រះគ្រឹស្នសម្លាប់បិសាចគោអារិស្ត និងបិសាចដំរីកុវលយបិទ ចំនួន២ផ្ទាំង (ផ្តែរប្រាសាទគុកតាពេជ្រ និងផ្តែរមិនស្គាល់ប្រភពនៅសារមន្ទីរខេត្ត) ចម្លាក់ព្រះគ្រឹស្នហែកនាគកាលិយ ចំនួន១ផ្ទាំង (ផ្តែរវត្តក្តីត្នោត) និងចម្លាក់ព្រះគ្រឹស្នទ្រភ្នំគោវធ៌ន ចំនួន១ផ្ទាំង (សសរផ្តោបប្រាសាទគុកនគរ)។ តើចម្លាក់ទាំង ៤ មានលក្ខណៈបែបណាខ្លះ?

ដំបូងយើងលើកយកចម្លាក់ព្រះគ្រឹស្នសម្លាប់បិសាចគោអារិស្ត និងបិសាចដំរីកុវលយបិទមកសិក្សាជាមុនសិន ដែលចម្លាក់ទាំងពីរ សិល្បករបុរាណឆ្លាក់នៅលើផ្តែរទ្វារដូចគ្នា ហើយអាយុកាលក៏ដូចគ្នាដែរ ពោលគឺស្ថិតនៅស.វ.ទី១១ (រូបលេខ២-៣)។ នៅក្នុងទេវកថាហិណ្ឌូបាននិទានថា៖ *ក្នុងពេលដែលព្រះគ្រឹស្នារស់នៅក្នុងភូមិវជ្រ ព្រះបាទកម្សនៅតែបញ្ជាឱ្យបិសាចជាច្រើនតាមសម្លាប់ទ្រង់។ ក្នុងគ្រាមួយ មានយក្សមួយឈ្មោះអារិស្ត ដែលមកប៉ុនប៉ងសម្លាប់ព្រះគ្រឹស្នបានប្រែក្រឡាជាសត្វគោមួយក្បាលដែលមានមាឌធំ ដែលបានធ្វើឱ្យមនុស្សម្នាជាច្រើនខ្លាចរអា ជាពិសេសគឺក្រចកជើងដែលអាចរញ្ជួយធរណីនិងស្នែងដ៏មុតស្រួចរបស់វា។ បិសាចគោបានព្យាយាមចូលទៅរស់នៅជាមួយហ្វូងគោដទៃទៀតក្នុងភូមិ ក្នុងបំណងឱ្យគោដទៃទៀតឈប់រវល់នឹងកូន និងឈប់បំបៅដោះកូន។*

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ដំណឹងនេះបានឮទៅដល់ព្រះក្រឹស្ណចុះមកអន្តរាគមន៍។ ទ្រង់បានប្រយុទ្ធជាមួយបិសាចគោអារិស្ត ដែលដំបូងឡើយបិសាចគោបានវាយប្រហារលើព្រះក្រឹស្ណមុន ស្របពេលនោះព្រះក្រឹស្ណក៏ចាប់ស្នែងគោគ្រវែងទៅយ៉ាងឆ្ងាយ ប៉ុន្តែបិសាចនោះនៅតែលោតមកវាយប្រហារព្រះក្រឹស្ណជាបន្ត ទើបធ្វើឱ្យទ្រង់ទ្រាំលែងបានក៏កាន់គោបង្វិល និងផ្ទាក់ទៅនឹងដី ហើយទាញយកស្នែងមួយរបស់បិសាចគោមកចាក់បិសាចគោនោះរហូតដល់ស្លាប់”។[១] ចំណែកឈុតរឿងព្រះក្រឹស្ណសម្លាប់បិសាចដំរីកុវលយបិទវិញ មាននិទាននៅក្នុងគម្ពីរភគវតបុរាណថា៖ “ថ្ងៃមួយនៅពេលដែលព្រះក្រឹស្ណ និងពលរាមនៅមធុរ មុនពេលចូលប្រកួតប្រាកចំបាប់ ពួកគេបានឮសំឡេងស្គរ និងសំឡេងគ្រហឹមមកពីសង្វៀន។ ក្នុងគ្រានោះមានដំរីមួយកំពុងបិទច្រកចូល ក្រោយមកមានការប្រយុទ្ធគ្នាយ៉ាងសាហាវបានកើតឡើង។ ដំរីចាប់ព្រះក្រឹស្ណនឹងប្រមោយរបស់វា ប៉ុន្តែព្រះក្រឹស្ណក៏រំអិលខ្លួនចេញ បន្ទាប់មកក៏ចាប់កន្ទុយដំរី ហើយទាញវាចេញយ៉ាងឆ្ងាយ ពេលដែលដំរីវាយប្រហារព្រះក្រឹស្ណម្តងទៀត ព្រះក្រឹស្ណក៏ចាប់កន្ទុយដំរីគ្រវែងទៅដី រួចកំទេចដើងរបស់វា”។[២] ត្រឡប់មកមើលចម្លាក់ព្រះក្រឹស្ណសម្លាប់បិសាចគោអារិស្ត និងសម្លាប់បិសាចដំរីកុលវយបិទនៅលើផ្តែរទាំងពីរវិញ មានលក្ខណៈខុសគ្នាតិចតួចប៉ុណ្ណោះ។ នៅលើផ្តែរប្រាសាទគុកតាពេជ្រ ស្រុកបារាយណ៍ សិល្បករឆ្លាក់តួអង្គព្រះក្រឹស្ណមានមាឌធំក្រអាញ នៅលើព្រះហស្តមានពាក់កងធំៗពីរជាន់ ហើយនៅលើព្រះសិរទំនងមានពាក់មកុដ (ចម្លាក់រលុប) (រូបលេខ២)។ ព្រះហស្តទាំងពីររបស់ព្រះក្រឹស្ណចាប់កាន់កន្ទុយបិសាចដំរី និងបិសាចគោ ក្នុងកម្ពស់ដៃស្មើៗគ្នា។ លក្ខណៈគួរកត់សម្គាល់នោះគឺ ក្បាលបិសាចគោអារិស្ត និងក្បាលដំរីកុលវយបិទ គេឆ្លាក់ជាប់ជាមួយក្បាច់ដងធ្នូរបស់ផ្តែរ ហើយម្យ៉ាងទៀតចម្លាក់មានភាពរលុបផង នាំឱ្យយើងពិបាកកំណត់ថា មួយណាជាតួអង្គបិសាចគោ មួយណាជាតួអង្គបិសាចដំរី។ ប៉ុន្តែបើមើលរូបខាងស្តាំ យើងឃើញមាននៅសល់ចម្លាក់ដូចប្រម៉ោយដំរី ដែលអាចឱ្យយើងសន្និដ្ឋានថារូបខាងស្តាំនោះ ជារូបបិសាចដំរី ហើយខាងឆ្វេងជារូបបិសាចគោ។ លក្ខណៈពិសេសមួយនោះគឺ សិល្បករបានឆ្លាក់បិសាចគោមានមាឌធំជាងដំរីដែលករណីនេះគេចង់បង្ហាញឱ្យ

[១] Roveda 2005: 80-89.

[២] Deydier 1952: 263.

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

ដឹងថា តួអង្គបិសាចគោអារិស្ដ គឺជាយក្សប្រែកាឡា ម៉្លោះហើយគោនោះក៏ត្រូវមានមាឌធំដូចយក្សដែរ។ ព្រះបាទទាំងពីររបស់ព្រះក្រឹស្ណកន្ទែកឆ្ងាយពី ដោយមានជុចជង្គង់បន្ដិចក្នុងកាយវិការមួយដែលរៀបនឹងបម្រុងគ្រវាត់គ្រវែងបិសាចទាំងពីរនោះ ចេញពីព្រះហស្ដ។ ចំណែកឯចម្លាក់នៅលើផ្ដែរទ្វារមួយមិនស្គាល់ប្រភព ដែលរក្សាទុកនៅសារមន្ទីរខេត្តវិញ យើងឃើញមានលក្ខណៈខុសគ្នា ត្រង់កាយវិការព្រះក្រឹស្ណចាប់លើបិសាចទាំងពីរនោះ (រូបលេខ៥)។ ព្រះហស្ដខាងស្ដាំ យើងឃើញសិល្បករឆ្លាក់ព្រះក្រឹស្ណចាប់ជើងបិសាចគោលើកឡើងលើខ្ពស់ដល់ត្រឹមព្រះភក្ត្រ និងខាងឆ្វេងចាប់កាន់ជើងដំរីលើកត្រឹមពោះ។រូបក្បាលបិសាចគោ និងដំរីនៅលើផ្ដែរទ្វារនេះ យើងឃើញគេឆ្លាក់មិនជាប់នឹងដងធ្នូដូចផ្ដែរមុនទេ ហើយទិសក៏មិនដូចគ្នាដែរ ព្រោះដំរីគេឆ្លាក់នៅខាងឆ្វេង និងគោនៅខាងស្ដាំវិញ។ ប៉ុន្ដែលក្ខណៈរួមមួយនោះគឺ ចម្លាក់លើផ្ដែរទ្វារនេះ នៅតែឃើញរូបដំរីតូចជាងរូបគោដូចគ្នា។

ដោយឡែក ចម្លាក់មួយទៀតដែលយើងនឹងលើកយកបង្ហាញនោះគឺ ចម្លាក់ព្រះក្រឹស្ណហែកនាគកាលិយឆ្លាក់នៅផ្ដែរទ្វារ ដែលរកឃើញនៅវត្តក្ដីត្នោត ស្រុកស្ទោង ខេត្តកំពង់ធំ (រូបលេខ៦)។ តាមគម្ពីរហិណ្ឌូរៀបរាប់ថា កាលណាក្រឹស្ណប្រយុទ្ធជាមួយនាគ នាគនោះឈ្មោះថា "អឃ" ហើយបើសិនក្រឹស្ណរាំនៅពីលើនាគ នាគនោះគឺឈ្មោះ "កាលិយ" ហើយជាទូទៅនៅក្នុងសិល្បៈខ្មែរចាប់ពីស.វ.ទី១០មក យើងឃើញគេឆ្លាក់ក្រឹស្ណរាំនៅលើនាគ និងចាប់ហែកនាគ។[៣] សាច់រឿងឈុតនេះមានដំណាលថា៖ "*ថ្ងៃមួយក្មេងៗគង្វាលបាននាំគ្នាលេងបាល់នៅមាត់ទន្លេកាលន្ទិ ពេលនោះព្រះក្រឹស្ណក៏មកលេងជាមួយក្មេងៗ ហើយក៏បានទាត់បាល់ចូលទៅក្នុងទឹកទន្លេ។ ក្មេងៗមានការខឹងសម្បារនឹងព្រះក្រឹស្ណយ៉ាងខ្លាំង ដ្បិតមិនមាននរណាហ៊ានចុះទៅក្នុងទន្លេនោះទេ ព្រោះគេដឹងថានៅក្នុងទន្លេមាននាគដែលមានពិសខ្លាំងរស់នៅ ដែលពីមុនមកធ្លាប់មានក្មេងៗ និងសត្វពាហនពុលស្លាប់។ ពេលនោះព្រះក្រឹស្ណក៏ចុះទៅក្នុងទន្លេរើសបាល់ ស្រាប់តែនាគកាលិយបានចេញមករុំព័ន្ធព្រះកាយទ្រង់។ ទ្រង់ក៏បានលោតចេញពីការរុំព័ន្ធ ហើយមកជិះពីលើនាគរាំរែកទន្រ្ទាំជើង និងចាប់ហែកនាគកាលិយនោះរហូតដល់ក្អួតឈាមស្ទើរនឹងស្លាប់ តែបានប្រពន្ធរបស់នាគចេញមកអង្វរកដល់ព្រះក្រឹស្ណកុំឱ្យសម្លាប់នាគកាលិយដែលជាប្ដីរបស់នាង។ ដោយ*

---

[៣] Dagens 1969: 180.

*ទឹកអាណិតនឹងក្ដីអង្វរកររបស់នាគញី ព្រះក្រឹស្ណក៏ទុកជីវិតឱ្យ តែបានបញ្ជាឱ្យនាគកាលិយនាំកូនចៅចេញពីទន្លេនេះឱ្យអស់ ចុះទៅនៅសមុទ្រវិញ។[៨] ចម្លាក់នៅលើផ្ដែរវត្តក្ដីត្នោត យើងឃើញសិល្បករឆ្លាក់រូបព្រះក្រឹស្ណក្នុងទម្រង់ជាកុមារ ព្រះបាទឆ្វេងជាក់ចំកនាគ ព្រះហស្ដទាំងពីរចាប់និងច្រានក្បាលនាគក្នុងទម្រង់ចាប់ហែកនាគ (ក្បាលនាគទំនងមាន ៦ ឬ ៧ តែដោយសាររលុបយើងមិនអាចមើលឃើញច្បាស់)។[៩] ជាទូទៅ សិល្បករខ្មែរប្រកាន់យកគោលការណ៍ពីរយ៉ាងក្នុងការឆ្លាក់ក្បាលនាគ គឺចំនួនសេស និងចំនួនគត់គូរ។ ចំនួនគត់គូរជាចំនួនដែលស្ថិតនៅក្នុងគោលការណ៍សូន្យ មានន័យថា "ស្លាប់"។[៦] ចំណែកឯចម្លាក់មួយទៀតជាឈុតព្រះក្រឹស្ណទ្រភ្នំគោវជ៌ន ឆ្លាក់នៅលើសសរផ្ដោបប្រាសាទគុកនគរ យើងពុំបានយកមករៀបរាប់ទៀតទេ ដោយសារនៅក្នុងអត្ថបទមុនធ្លាប់និយាយម្ដងរួចមកហើយ (រូបលេខ៧)។*

## ឯកសារយោង


***ម៉ង់ រ៉ាលី***

២០២១, *កំពង់ធំ ប្រវត្តិសាស្ត្រ និងប្រាសាទបុរាណ*, ភ្នំពេញ

**Brand, Michael & Chuch Phoeun**

1992, The age of Angkor, *Canberra*, Australia

**Dimmit, Cornelia & Buitenen, J.A.B**

1978, Classical Hindu Mythology, USA

**Roveda, Victorio**

2005, "*Image of the gods*", Bangkok

**Wendy Doniger O'Flaherty**

1975, *Hindu myths*, Middlesex, England


---

[៨] Cornelia & Buitenen 1978: 114-116; Wendy Doniger 1975: 221-228; Roveda 2005: 79.

[៩] ម៉ង់ រ៉ាលី ២០២១: ៣៤៦។

[៦] Brand & Chuch 1992: 80.



រូបលេខ១៖ ចម្លាក់ព្រះក្រឹស្ណទ្រភ្នំគោវធ៌ននៅសំបូរព្រៃគុក



រូបលេខ២៖ ចម្លាក់ព្រះក្រឹស្ណសម្លាប់បិសាចដំរីនិងគោ នៅប្រាសាទគុកតាពេជ្រ



រូបលេខ៣៖ ចម្លាក់ព្រះក្រឹស្ណសម្លាប់បិសាចដំរីនិងគោ នៅសារមន្ទីរខេត្តកំពង់ធំ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី





រូបលេខ២៤ និង៥៖ លម្អិតចម្លាក់ព្រះក្រឹស្ណសម្លាប់បិសាចដំរីនិងគោនៅលើផ្តែរគុកតាពេជ្រ និងផ្តែរមិនស្គាល់ប្រភព (សារមន្ទីរខេត្តកំពង់ធំ)



រូបលេខ២៦៖ ចម្លាក់ព្រះក្រឹស្ណហែកនាគកាលិយ នៅលើផ្តែរវត្តក្តីត្នោត



រូបលេខ២៧៖ លម្អិតចម្លាក់ព្រះក្រឹស្ណហែកនាគកាលិយ នៅលើផ្តែរវត្តក្តីត្នោត



រូបលេខ២៨៖ ចម្លាក់ព្រះក្រឹស្ណទ្រភ្នំគោវធ៌ន នៅលើសសរផ្តោបប្រាសាទគុកនគរ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី